Save the Children | Helen Keller INTERNATIONAL | unicef | World Health Organization | World Vision

# ខែ ឧសភា ឆ្នាំ ២០១៤
# សេចក្តីថ្លែងការណ៍រួមអំពីផលិតផលជំនួសទឹកដោះម្តាយក្នុងប្រទេសកម្ពុជា

ការសិក្សានាពេលថ្មីៗមួយអំពីការខាតបង់ផ្នែកសេដ្ឋកិច្ច ដោយសារបញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជា បានគូសបញ្ជាក់ឲ្យឃើញថា កុមារមានអាយុក្រោម៦ខែ ប្រមាណ១,៣៨៧នាក់បានស្លាប់ជារៀងរាល់ឆ្នាំ ដែលបណ្តាលមកពីការអនុវត្តការបំបៅកូនដោយទឹកដោះម្តាយមិនបានល្អត្រឹមត្រូវ ដែលចំនួននេះប្រហែលជាស្មើនឹង ១០% នៃករណីស្លាប់ទាំងអស់របស់កុមារអាយុក្រោម៦ខែ។

បើទោះបីជាកម្ពុជាបានធ្វើឲ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់លើការកាត់បន្ថយអត្រាមរណភាពកុមារចាប់តាំងពីឆ្នាំ២០០០មកក៏ដោយ ប៉ុន្តែកុមារកម្ពុជារហូតដល់ទៅ៤០% នៅមានបញ្ហាកង្វះអាហារូបត្ថម្ភ ខណៈដែលកំណើននៃការផ្សព្វផ្សាយ និង ការប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយក្នុងប្រទេសកម្ពុជា កំពុងតែមានការកើនឡើងគួរឱ្យព្រួយបារម្ភ។ ការប្រើប្រាស់ទឹកដោះគោម្សៅផ្សំតាមរូបមន្តសម្រាប់ចិញ្ចឹមទារក និងផលិតផលជំនួសទឹកដោះម្តាយដទៃទៀត មិនត្រឹមតែរាំងដល់ការរីកចំរើនបន្តទៀតលើបញ្ហាកង្វះអាហារូបត្ថម្ភប៉ុណ្ណោះទេ ប៉ុន្តែវាអាចធ្វើឱ្យវឌ្ឍនភាពដែលសម្រេចបានតាមរយៈការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ និងការបន្តបំបៅដោះកូន (ដែលអត្រាបានកើនឡើងពី ១១% ទៅ ៧៤% នៅចន្លោះឆ្នាំ២០០០ និង ឆ្នាំ២០១០) មានការធ្លាក់ចុះមកវិញ។ លើសពីនេះទៅទៀត បញ្ហានេះអាចគំរាមកំហែងចំពោះវឌ្ឍនភាពដែលសម្រេចបានទាក់ទងទៅនឹងការកាត់បន្ថយអត្រាមរណភាពរបស់កុមារផងដែរ។

សេដ្ឋកិច្ចដែលកំពុងតែអភិវឌ្ឍន៍ដូចនៅក្នុងប្រទេសកម្ពុជា គឺជាប្រភពមួយដ៏សំខាន់នៃកំណើនប្រាក់ចំណូលរបស់ឧស្សាហកម្មនៃផលិតផលជំនួសទឹកដោះម្តាយ ហើយឥទ្ធិពលរបស់ក្រុមហ៊ុនផលិតផលជំនួសទឹកដោះម្តាយមកពីបរទេសក៏កំពុងតែមានការកើនឡើងដែរ។ លទ្ធផលបឋមនៃការស្រាវជ្រាវដែលបានធ្វើឡើងនៅរាជធានីភ្នំពេញ បង្ហាញឱ្យឃើញថាមានផលិតផលជំនួសទឹកដោះម្តាយយ៉ាងច្រើនគួរឱ្យភ្ញាក់ផ្អើលរហូតដល់ទៅ១១៣ប្រភេទខុសៗគ្នាដាក់លក់នៅលើទីផ្សារ។ កំណើននៃចំនួនផលិតផលហើយងាយស្រួលស្វែងរកទាំងអស់នេះ រួមជាមួយកំណើននៃការផ្សព្វផ្សាយលក់ និងការធ្វើទីផ្សារផលិតផល អាចធ្វើឱ្យព័ត៌មានអំពីអាហារូបត្ថម្ភល្អ និងការអនុវត្តន៍ល្អត្រូវបានចុះខ្សោយ។ ការអង្កេតមួយនាពេលថ្មីៗនេះទៅលើម្តាយដែលមានកូនអាយុក្រោម២ឆ្នាំបានបង្ហាញថា ម្តាយចំនួន៨៦% បានឃើញ លឺ ឬ អានការផ្សព្វផ្សាយពាណិជ្ជកម្មអំពីផលិតផលជំនួសទឹកដោះម្តាយ ចាប់តាំងពីកូនរបស់ពួកគាត់កើត។

ការវិភាគបន្ថែមដ៏ស៊ីជម្រៅមួយទៅលើការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ២០១០ បានបង្ហាញថាការប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយ នៅតំបន់ទីក្រុង និង នៅតាមមូលដ្ឋានសុខភាពឯកជន ក៏កំពុងមានការកើនឡើងផងដែរ។ កុមារ១នាក់ ក្នុងចំណោមកុមារ៥នាក់នៅតំបន់ទីក្រុង ឬ នៅក្នុងគ្រួសារដែលមានកម្រិតទ្រព្យធនខ្ពស់បំផុត គឺប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយដើម្បីចិញ្ចឹមកូន និង ស្ត្រី១នាក់ ក្នុងចំណោមស្ត្រី៤នាក់ ដែលសម្រាលកូននៅគ្លីនិកឯកជន ប្រើប្រាស់ទឹកដោះគោម្សៅផ្សំតាមរូបមន្តសម្រាប់ចិញ្ចឹមទារក ដែលចំនួននេះមានកម្រិតខ្ពស់ជាងស្ត្រីដែលសម្រាលកូននៅតាមមន្ទីរពេទ្យរដ្ឋរហូតដល់ទៅ៣ដង។ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលត្រូវផ្តល់ព័ត៌មានត្រឹម

ត្រូវបន្ថែមទៀតដល់ប្រជាជនកម្ពុជាថា ទឹកដោះម្តាយគឺជាជម្រើសប្រសើរបំផុត ដើម្បីឱ្យកុមារទទួលបានអាហារូបត្ថម្ភល្អប្រសើរ។

តាមការអង្កេតនាពេលថ្មីៗដោយអង្គការសង្គមស៊ីវិលបង្ហាញឱ្យដឹងថា មានក្រុមហ៊ុនតិចតួចប៉ុណ្ណោះ (ប្រសិនក្នុងករណីដែលមាន) ដែលអនុវត្តតាមច្បាប់ដែលមានស្រាប់នៅកម្ពុជា ត្រូវបានរៀបចំឡើង ដើម្បីធានាការពារចំពោះអាហារូបត្ថម្ភរបស់ទារកទើបកើត និងកុមារតូចៗ។ អនុក្រឹត្យលេខ ១៣៣ (ឆ្នាំ២០០៥) បង្កើតឡើងដើម្បីការពារ និងលើកកម្ពស់ការបំបៅកូនដោយទឹកដោះម្តាយ តាមរយៈការហាមឃាត់រាល់ការផ្សព្វផ្សាយពាណិជ្ជកម្មបំភាន់អំពីផលិតផលជំនួសទឹកដោះម្តាយ។ អនុក្រឹត្យនេះគឺក្របខ័ណ្ឌគតិយុត្តិជាលាយល័ក្ខអក្សរមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងដែលអនុវត្ត*ក្រមអន្តរជាតិនៃការផ្សព្វផ្សាយលក់ផលិតផលជំនួសទឹកដោះម្តាយ* (អនុម័តដោយសន្និបាតសុខភាពពិភពលោក ក្នុងឆ្នាំ១៩៨១) និងជាឧបករណ៍ត្រួសត្រាយក្នុងការលើកកម្ពស់អាហារូបត្ថម្ភល្អសម្រាប់ទារក និងកុមារតូចក្នុងប្រទេសកម្ពុជា។ បើទោះបីជាមានក្រសួងនានារបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធគាំទ្រច្បាប់នេះ និង បានអនុម័តសេចក្តីប្រកាសរួម (លេខ ០៦១ ឆ្នាំ២០០៧) ដើម្បីឱ្យការអនុវត្តន៍មានប្រសិទ្ធភាពខ្លាំងក្លាក៏ដោយ នៅតែមានក្រុមហ៊ុនជាច្រើនរំលោភបំពានលើច្បាប់នេះ។

ផលិតផលជំនួសទឹកដោះម្តាយទាំងនោះគ្រាន់តែគោរពដោយផ្អែកទៅតាមល័ក្ខខ័ណ្ឌតម្រូវចំពោះការបិតស្លាកសញ្ញាប៉ុណ្ណោះ។ ដោយឡែក ល័ក្ខខ័ណ្ឌដែលតម្រូវឱ្យប្រតិបត្តិតាមមួយចំនួនទៀតមិនត្រូវបានគេបន្តយកចិត្តទុកដាក់អនុវត្តឡើយ។ បញ្ហានេះ ធ្វើឱ្យការយល់ដឹងនៅមានកម្រិត និង ការទទួលបានព័ត៌មានមិនត្រឹមត្រូវអំពីការអនុវត្តដ៏ប្រសើរបំផុតទាក់ទងទៅនឹងការអនុវត្តការចញ្ចឹមទារក និងការផ្តល់អាហារដល់កុមារតូច ព្រមទាំងបង្កឱ្យមានការគំរាមកំហែងដ៏ពិតប្រាកដមួយចំពោះអាហារូបត្ថម្ភកុមារទូទាំងព្រះរាជាណាចក្រកម្ពុជា។បន្ថែមពីលើការរំលោភបំពានចំពោះការបិតស្លាកសញ្ញា ក្រុមហ៊ុនមួយចំនួនអនុវត្តការធ្វើទីផ្សារ ដែលត្រូវបានហាមឃាត់ទាំងស្រុងនៅក្នុងអនុក្រឹត្យនេះ។ យោងតាមការសង្កេតនាពេលថ្មីៗនេះ ហាងចំនួន៨១%នៅរាជធានីភ្នំពេញដែលលក់ផលិតផលជំនួសទឹកដោះម្តាយ បានផ្តល់ការផ្សព្វផ្សាយផ្ទាល់នៅក្នុងហាងសម្រាប់ផលិតផលទាំងនោះ ដែលការអនុវត្តនេះត្រូវបានអនុក្រឹត្យហាមឃាត់ និង គ្មានការយល់ព្រមឱ្យធ្វើយ៉ាងដូច្នេះពីក្រសួងសុខាភិបាលឡើយ។

ការរំលោភបំពានក៏កើតមានផងដែរនៅតាមគ្រឹះស្ថានផ្តល់សេវាសុខភាព (មណ្ឌលសុខភាព មន្ទីរពេទ្យរដ្ឋ មន្ទីរពេទ្យឯកជន ឬ គ្លីនិក) ទាំងរដ្ឋ និង ឯកជន។ ការផ្សព្វផ្សាយផលិតផលជំនួសទឹកដោះម្តាយនៅតាមគ្រឹះស្ថានផ្តល់សេវាសុខភាព ត្រូវបានអនុក្រឹត្យលេខ ១៣៣ ហាមឃាត់ ប៉ុន្តែការស្រាវជ្រាវនាពេលថ្មីៗនេះ បានរកឃើញថា ម្តាយចំនួន៣២% ដែលទើបសម្រាលកូន បានរាយការណ៍ឱ្យដឹងថា ពួកគេបានឃើញការបិតស្លាកសញ្ញាផលិតផលជំនួសទឹកដោះម្តាយនៅលើឧបករណ៍ ឬ សម្ភារៈក្នុងគ្រឹះស្ថានផ្តល់សេវាសុខភាព។ បញ្ហានេះ បណ្តាលឱ្យមានការភាន់ច្រឡំ រវាងបច្ចេកទេសធ្វើទីផ្សារ និង ដំបូន្មានវេជ្ជសាស្ត្រ និង អាចធ្វើឱ្យឪពុកម្តាយ និង អ្នកថែទាំកុមារយល់ខុសអំពីប្រសិទ្ធភាពរបស់ទឹកដោះគោម្សៅធៀបនឹងទឹកដោះម្តាយ។

យើងត្រូវខិតខំឱ្យបានខ្លាំងក្លា ដើម្បីធានាថា ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ និងការបន្តបំបៅដោះកូនត្រូវបានមើលឃើញថាជាជម្រើសល្អ ឬ ផ្តល់សុខភាពល្អជាង ការចិញ្ចឹមទារកនិងកុមារតូចដោយផលិតផលជំនួសទឹកដោះម្តាយ។ ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានវឌ្ឍនភាពជាវិជ្ជមាន ចំពោះការ

ធានាអនុវត្តអនុក្រឹត្យលេខ ១៣៣។ ចំនុចនេះបានទទួលការស្វាគមន៍យ៉ាងខ្លាំង ហើយយើងសូមលើកទឹកចិត្តរដ្ឋាភិបាល ឱ្យពង្រឹងបន្ថែមទៅលើចលនា និង ការប្តេជ្ញាចិត្តផ្នែកនយោបាយនេះដើម្បីសម្រេចបានវឌ្ឍនភាពបន្ថែមទៀត។

អំឡុងថ្ងៃទី១៩និងទី២៤ ខែឧសភា ឆ្នាំ២០១៤ ការចិញ្ចឹមទារក និងកុមារតូច នឹងត្រូវបានបញ្ចូលជាចំនុចសំខាន់មួយដែលត្រូវយកមកធ្វើការឆ្លុះបញ្ចាំងនៅក្នុងសន្និបាតសុខភាពពិភពលោកលើកទី៦៧ ព្រមទាំងផ្តល់ឱកាសដើម្បីធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល និង ការចាត់ទុកបញ្ហាអាហារូបត្ថម្ភកុមារជាបញ្ហាអាទិភាពក្នុងប្រទេសកម្ពុជា ដោយផ្តោតយកចិត្តទុកដាក់សំខាន់លើរយៈពេល១០០០ថ្ងៃដំបូងនៃជីវិតរបស់កុមារ។ ភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍រួមនេះ សូមអំពាវនាវឱ្យក្រុមហ៊ុនផលិតផលជំនួសទឹកដោះម្តាយ និង អាហារបន្ថែមទាំងអស់ អនុវត្តទាំងស្រុងឱ្យបានខ្ជាប់ខ្ជួនទៅតាមល័ក្ខខ័ណ្ឌតម្រូវដែលបានកំណត់នៅក្នុងអនុក្រឹត្យលេខ ១៣៣ និង សូមអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការបន្ថែមទៀត ដើម្បីធានាថាអនុក្រឹត្យលេខ ១៣៣នេះ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

លោកស្រី Rana Flowers
តំណាងមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ
កាលបរិច្ឆេទ៖ 06/05/14

វេជ្ជបណ្ឌិត Dong-il Ahn
តំណាងអង្គការសុខភាពពិភពលោកប្រចាំប្រទេសកម្ពុជា
កាលបរិច្ឆេទ៖ 6 May 2014

លោក Jason Evans
នាយកប្រចាំប្រទេសកម្ពុជា អង្គការទស្សនពិភពលោកអន្តរជាតិ
កាលបរិច្ឆេទ៖ 6.05.14

លោក Keith Porter
នាយកប្រចាំប្រទេស អង្គការហេឡែនខេលល័រអន្តរជាតិកម្ពុជា
កាលបរិច្ឆេទ៖ 6.05.14

លោក Andrew Moore
នាយកប្រចាំប្រទេស អង្គការហ្សេវឺផែលខ្មែរកម្ពុជា
កាលបរិច្ឆេទ៖ 06.05.14